ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា និងមជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡាចំណុះអគ្គនាយកដ្ឋានកីឡា នៃក្រសួងអប់រំ យុវជន និងកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតនាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡានិងមជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡាចំណុះអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា២ .-**

នាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា មានភារកិច្ចដូចតទៅ៖

- រៀបចំ គ្រប់គ្រងព្រឹត្តិការណ៍កីឡា និងការប្រកួត
- សិក្សា ស្រាវជ្រាវ វិភាគ វាយតម្លៃ និងរៀបចំយន្តការការប្រកួតនិងព្រឹត្តិការណ៍កីឡាមានលក្ខណៈជាតិនិងអន្តរជាតិ
- រៀបចំគោលការណ៍និងលិខិតបទដ្ឋានគតិយុត្តនៃការប្រកួតនិងព្រឹត្តិការណ៍កីឡា
- រៀបចំផែនការប្រកួតនិងព្រឹត្តិការណ៍កីឡា
- សហការជាមួយអង្គការសង្គមវិជ្ជាជីវៈកីឡា អង្គការសង្គមកីឡា និងភាគីពាក់ព័ន្ធដើម្បីរៀបចំការប្រកួតនិងព្រឹត្តិការណ៍កីឡា
- រៀបចំតាមដាន វាយតម្លៃ ត្រួតពិនិត្យ និងកត់ត្រាគុណផលកីឡា ដើម្បីដាក់ជូនគណៈកម្មការបច្ចេកទេសជ្រើសរើសកីឡាករកម្រិតខ្ពស់ ដើម្បីពិនិត្យនិងសម្រេច
- សិក្សារៀបចំយុទ្ធសាស្ត្រនិងស្វែងរកចលនូបត្ថម្ភ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡាប្រគល់ជូន។

**មាត្រា៣ .-**

នាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា ដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៤ .-**

មជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡា មានភារកិច្ចដូចតទៅៈ

- ប្រមូលទិន្នន័យព័ត៌មានពាក់ព័ន្ធនឹងការហាត់ហ្វឹកហ្វឺន ការប្រកួត គុណផលកីឡា និងសុខភាពរបស់កីឡាករ
- រៀបចំកម្មវិធីតាមប្រព័ន្ធព័ត៌មានវិទ្យានិងវិទ្យាសាស្ត្រកុំព្យូទ័រ ដើម្បីស្រង់ស្ថិតិ គ្រប់គ្រងព័ត៌មានទាក់ទងនឹងការហាត់កីឡាដើម្បីសុខភាព
- រៀបចំផ្សព្វផ្សាយព័ត៌មានកីឡាដែលប្រមូលបានពីបណ្ដាញផ្សព្វផ្សាយព័ត៌មានកីឡា បណ្ដាញគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គមផ្សេងៗទៀតឱ្យបានទូលំទូលាយ
- រៀបចំកម្មវិធីប្រើប្រាស់វិទ្យាសាស្ត្រកុំព្យូទ័រ ដើម្បីចូលរួមក្នុងការហាត់ហ្វឹកហ្វឺនការប្រកួតលក្ខណៈជាតិឬអន្តរជាតិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានកីឡាប្រគល់ជូន។

**មាត្រា៥ .-**

មជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡា ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ប្រធានមជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡាមានឋានៈស្មើប្រធាននាយកដ្ឋាននិងអនុប្រធានមជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡាមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា និងមជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហ ៩ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ